ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិភាតរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៤៩ អនក្រ.បក ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកំណត់អត្រាបែងចែករំលែកចំណូលពីសេវាសាធារណៈនិងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិជូនជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីប្រភពធនធាន ទំហំធនធាន ការគ្រប់គ្រង នីតិវិធីនៃការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិភាតរភាព ដើម្បីបង្កើនធនធានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព និងសមធម៌ ព្រមទាំងផ្ដល់លទ្ធភាពសមស្របឆ្លើយតបទៅនឹងមុខងារ និងការទទួលខុសត្រូវក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តនៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២
## ប្រភពធនធាន

**មាត្រា៣.-**

ប្រភពធនធាននៃមូលនិធិភាតរភាពរួមមាន៖

- ការបែងចែកចំណូលពីសេវាសាធារណៈរបស់រដ្ឋបាលកណ្ដាល ចំនួន ១៥% នៃចំណែកសាច់ប្រាក់ដែលបានបង់ចូលគណនីទោលរតនាគារជាក់ស្ដែងនៅក្នុងឆ្នាំអនុវត្តថវិកា ដែលស្ថិតក្នុងមុខងារគ្រប់គ្រង និងប្រមូលចំណូលដោយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ការបែងចែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការសម្រេចពីរាជរដ្ឋាភិបាល និង
- ប្រភពធនធានស្របច្បាប់ផ្សេងៗទៀត។

**មាត្រា៤.-**

ការទទួលបានប្រភពធនធានស្របច្បាប់ផ្សេងៗទៀត ត្រូវគ្រប់គ្រងនិងចាត់ចែងតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការបង្កើត និងការគ្រប់គ្រង

**មាត្រា៥.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាម្ចាស់គណនីមូលនិធិភាតរភាព ដែលបានបង្កើត និងរក្សាទុកនៅគណនីមួយនៅរតនាគារជាតិ។

**មាត្រា៦.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រង និងចាត់ចែងមូលនិធិភាតរភាព ដូចខាងក្រោម៖

- រៀបចំវិភាជធនធានប្រចាំឆ្នាំ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលទទួលបានពីមូលនិធិភាតរភាព
- ជូនដំណឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ អំពីទំហំធនធាន ដែលត្រូវទទួលបានពីការវិភាជប្រចាំឆ្នាំ
- រៀបចំការផ្ទេរធនធានពីមូលនិធិភាតរភាព ជូនរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ
- ត្រួតពិនិត្យ និងតាមដានការអនុវត្តមូលនិធិភាតរភាព និង
- ត្រួតពិនិត្យ និងតាមដានការផ្ទេរធនធានពីក្រសួង ស្ថាប័នពាក់ព័ន្ធចូលមូលនិធិភាតរភាព។

**មាត្រា៧.-**

អត្រានៃការផ្ទេរធនធានពីមូលនិធិភាតរភាព ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំនួន ២៥% ត្រូវបានបែងចែកជូនរដ្ឋបាលក្រុង ស្រុកទូទាំងប្រទេស តាមរូបមន្ត និងអត្រាដូចមានចែងក្នុងមាត្រា៨ នៃអនុក្រឹត្យនេះ
- ចំនួន ២៥% ត្រូវបានបែងចែកជូនរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេស តាមរូបមន្ត និងអត្រាដូចមានចែងក្នុងមាត្រា៨ នៃអនុក្រឹត្យនេះ
- ចំនួន ៥% ត្រូវបានបែងចែកសម្រាប់ការធ្វើអន្តរាគមន៍ដល់រដ្ឋបាលឃុំ សង្កាត់ ដែលមានស្ថានភាពភូមិសាស្ត្រពិសេស ឬមានតម្រូវការចាំបាច់គាំទ្រដោយឡែកសម្រាប់ការអភិវឌ្ឍដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងគាំទ្រដល់ចលនាប្រកួតប្រជែង ឬយន្តការផ្តល់ការលើកទឹកចិត្តលើការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់រដ្ឋបាលឃុំ សង្កាត់ ដែលមានស្ថានភាពភូមិសាស្ត្រពិសេស ឬមានតម្រូវការចាំបាច់គាំទ្រដោយឡែកសម្រាប់ការអភិវឌ្ឍដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងរូបមន្ត និងសន្ទស្សន៍សម្រាប់វិភាជន៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ចំនួន ១៥% ត្រូវបានបែងចែកសម្រាប់អនុវត្តយន្តការផ្តល់ហិរញ្ញប្បទានមានលក្ខណៈជាការប្រកួតប្រជែងផ្អែកលើសមិទ្ធកម្ម។ ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រប់គ្រង ចាត់ចែង ប្រើប្រាស់ និងវិភាជធនធានបានពីមូលនិធិភាគរភាពនេះស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និង
- ចំនួន ៣០% ត្រូវបានបែងចែកសម្រាប់ការធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាដែលមានសារៈសំខាន់ជាសារវ័ន្ត នៅពេលរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រឈមនឹងគ្រោះអាសន្នបន្ទាន់នានា មានជាអាទិ៍ ការឆ្លងរាលដាលនៃជំងឺកាចសាហាវ ឬគ្រោះមហន្តរាយធម្មជាតិ និងមានតម្រូវការហេដ្ឋារចនាសម្ព័ន្ធចាំបាច់និងបន្ទាន់ផ្សេងៗទៀត ដែលមានការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា៨.-**

ការវិភាជធនធានពីមូលនិធិភាគរភាព ជូនរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់គោលដៅនីមួយៗ ត្រូវបានគណនាដោយផ្អែកលើរូបមន្ត និងអត្រាដូចខាងក្រោម៖

- រដ្ឋបាលក្រុង ស្រុក៖
  - ចំនួន ៤០% ជាចំណែកស្មើគ្នា ត្រូវបានបែងចែកស្មើៗគ្នា
  - ចំនួន ៣០% ត្រូវបានបែងចែកតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋ និង
  - ចំនួន ៣០% ត្រូវបានបែងចែកតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រ។
- រដ្ឋបាលឃុំ សង្កាត់៖
  - ចំនួន ៤០% ជាចំណែកស្មើគ្នា ត្រូវបានបែងចែកស្មើៗគ្នា
  - ចំនួន ៣០% ត្រូវបានបែងចែកតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋ
  - ចំនួន ៣០% ត្រូវបានបែងចែកតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រ។

## ជំពូកទី៤
## ការគ្រោង ការប្រើប្រាស់ និងការផ្ទេរធនធានមូលនិធិភាគរភាព

**មាត្រា៩.-**

ធនធានមូលនិធិភាគរភាព ដែលត្រូវបែងចែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រោងឥណទានថវិកាក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**មាត្រា១០.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ត្រូវគណនានិងជូនដំណឹងជាផ្លូវការអំពីទំហំធនធានវិភាជន៍ដែលរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវទទួលបាននៅឆ្នាំបន្ទាប់ សម្រាប់រៀបចំគម្រោងថវិកាប្រចាំឆ្នាំយ៉ាងយូរបំផុតត្រឹមដំណាច់ខែមិថុនា។

**មាត្រា១១.-**

រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវគ្រោង និងប្រើប្រាស់ថវិកាដែលទទួលបានពីមូលនិធិភាគរភាពសម្រាប់ចំណាយអភិវឌ្ឍន៍។ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់អាចរៀបចំជាគម្រោងអភិវឌ្ឍន៍ដោយឡែក ឬដាក់បញ្ចូលជាមួយគម្រោងអភិវឌ្ឍន៍ដែលទទួលបានពីប្រភពមូលនិធិក្រុង ស្រុក ឬមូលនិធិឃុំ សង្កាត់ ឬពីប្រភពស្របច្បាប់ដទៃទៀត ដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិធាន នីតិវិធី និងលក្ខខណ្ឌនៃការគ្រោង និងការប្រើប្រាស់ថវិកាដែលទទួលបានពីមូលនិធិភាគរភាព ដូចគ្នាទៅនឹងការគ្រោងនិងការប្រើប្រាស់ថវិកានៃសមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មាត្រា១២.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ទេរធនធានពីមូលនិធិភាគរភាព ជូនរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ បន្ទាប់ពីក្រសួង ស្ថាប័នពាក់ព័ន្ធ បោះផ្សាយអាណត្តិបើកប្រាក់ដែលត្រូវចែករំលែកចំណូលពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិ ផ្ទេរចូលមូលនិធិភាគរភាពរួចរាល់។

**មាត្រា១៣.-**

សមតុល្យចុងឆ្នាំរបស់មូលនិធិភាគរភាព ត្រូវយោងទៅឆ្នាំបន្ទាប់។

**មាត្រា១៤.-**

ក្រសួងមហាផ្ទៃ ត្រូវចូលរួមគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តគម្រោង ដែលហិរញ្ញប្បទានដោយធនធានពីមូលនិធិភាគរភាព។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សាក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ